ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# កម្មវិធីវិនិយោគសាធារណៈ
# ៣ឆ្នាំរំកិល
# ២០១៥ - ២០១៧

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ
នាថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៤

រៀបចំដោយក្រសួងផែនការ

# បុព្វកថា

*សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន* នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានប្រសាសន៍បញ្ជាក់ឲ្យដឹងថា **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.) ២០១៤-២០១៨** គឺជាឯកសារសំខាន់មួយសម្រាប់គ្រប់គ្រងការវិនិយោគនិងការអភិវឌ្ឍលើវិស័យសាធារណៈនៅកម្ពុជា។

ចាប់តាំងពីឆ្នាំ១៩៩៦ ក្រសួងផែនការជាអ្នកទទួលខុសត្រូវក្នុងការរៀបចំ**កម្មវិធីវិនិយោគសាធារណៈ (ក.វ.ស.) ៣ឆ្នាំរំកិល** ជារៀងរាល់ឆ្នាំ ដើម្បីឆ្លើយតបទៅនឹងអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់តម្រូវការជំនួយវិនិយោគជាទុន និងជំនួយបច្ចេកទេសក្នុងការអនុវត្ត**ផ.យ.អ.ជ.**។ ក្នុងការរៀបចំ**ក.វ.ស. ៣ឆ្នាំរំកិល** ឆ្នាំ២០០៦-២០០៨ ឆ្នាំ២០០៧-២០០៩ ឆ្នាំ២០០៨-២០១០ ឆ្នាំ២០០៩-២០១១ ឆ្នាំ២០១០-២០១២ ឆ្នាំ២០១១-២០១៣ ឆ្នាំ២០១២-២០១៤ ឆ្នាំ២០១៣-២០១៥ ឆ្នាំ២០១៤-២០១៦ និង ឆ្នាំ២០១៥-២០១៧ ការវិភាជថវិកាបានឆ្លើយតបទៅនឹងការវិភាជដែលមានចែងនៅក្នុង**ផ.យ.អ.ជ. ២០០៦-២០១០ ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣** និង**ផ.យ.អ.ជ. ២០១៤-២០១៨**។

ក្រសួងផែនការបានបន្តធ្វើការកែសម្រួលបន្ថែមទៀតលើដំណើរការរៀបចំ**ក.វ.ស. ៣ឆ្នាំរំកិល ២០១៥-២០១៧** ដោយបានរៀបចំការពិភាក្សាដោយផ្ទាល់ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង បណ្តាក្រសួង ស្ថាប័ននីមួយៗ ដើម្បីធានាថាការធ្វើទិន្នន័យគម្រោងរបស់បណ្តាក្រសួង ស្ថាប័នទាំងអស់សម្រាប់រៀបចំ**ក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧** បានឆ្លើយតបទៅនឹងអាទិភាពរបស់**ផ.យ.អ.ជ.**។

**ផ.យ.អ.ជ. ២០១៤-២០១៨** បានបញ្ជាក់យ៉ាងច្បាស់លាស់ពីទំនាក់ទំនងនៃ**ផ.យ.អ.ជ. ក.វ.ស. ៣ឆ្នាំរំកិល ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងថវិកាប្រចាំឆ្នាំ**។ បច្ចុប្បន្ននេះ ថ្នាក់ដឹកនាំជាន់ខ្ពស់របស់ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា បាននិងកំពុងសម្របសម្រួលនិងប្រឹងប្រែងទាំងអស់គ្នាដើម្បីធានាបាននូវសុខដុមនីយកម្មការងារផែនការចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ។

ខ្ញុំមានសេចក្តីរីករាយ និងសូមធ្វើការបង្ហាញនូវ**ក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧** សម្រាប់ជាព័ត៌មាន និងការប្រើប្រាស់របស់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងដៃគូអភិវឌ្ឍ។ សូមឆ្លៀតយកឱកាសនេះដើម្បីបញ្ជាក់ឡើងវិញម្តងទៀត និងជំរុញដល់ដៃគូអភិវឌ្ឍដែលផ្តល់ការជួយឧបត្ថម្ភគាំទ្រដល់ប្រទេសកម្ពុជាត្រូវមានមូលដ្ឋានពិនិត្យលើគម្រោង**សម្រាប់អនុវត្តផ.យ.អ.ជ.** នៃបញ្ជីគម្រោង**ក.វ.ស. ៣ឆ្នាំរំកិល ២០១៥-២០១៧** ដែលនឹងនាំយើងឈានទៅសម្រេចបាននូវគោលបំណងនិងអាទិភាពដែលមានចែងនៅក្នុង**ផ.យ.អ.ជ.** និងដើម្បីកាត់បន្ថយភាពក្រីក្រនិងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។

*ក្រសួងផែនការ*

*ខែ ឆ្នាំ២០១៤*

*ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ*

**ឆាយ ថន**

# សញ្ញាជាតិនិងទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា





# មាតិកា

ទំព័រ


បុព្វកថា ........................................................................................................ i
សញ្ញាជាតិនិងទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា ........................................................... ii
មាតិកា ........................................................................................................ iii

*ជំពូកទី១- សេចក្តីផ្តើម*

ដំណើរការសុខដុមនីយកម្មការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋនិងហិរញ្ញប្បទានសហប្រតិបត្តិការ ............................................................................. ១
វិធីសាស្រ្តសម្រាប់រៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០១៥-២០១៧ ............. ២

*ជំពូកទី២-ទស្សនវិស័យសេដ្ឋកិច្ចឆ្នាំ២០១៥-២០១៧* ........................................ ៦

ស្ថានភាពទូទៅនៃកំណើនផលិតផលក្នុងស្រុកសរុប ២០១៥-២០១៧ ......................... ៦
អត្រាកំណើនផ.ស.ស.ពិត(ថ្លៃថេរឆ្នាំ២០០០)ដោយសកម្មភាពសេដ្ឋកិច្ច........................៧
ការវិនិយោគដែលចាំបាច់ដើម្បីសម្រេចនូវកំណើនផ.ស.ស.ដែលបានគ្រោងទុក ............... ៩
ចំណូលនិងចំណាយថវិកា២០១៥-២០១៧.......................................................... ១២
ចំណុចដៅនៃការកៀរគរធនធានសម្រាប់ការវិនិយោគរបស់វិស័យសាធារណៈឆ្នាំ២០១៥-២០១៧ ................................................................................................ ១៣

*ជំពូកទី៣- កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០១៥-២០១៧*............... ១៧

*ជំពូកទី៤- សេចក្តីសន្និដ្ឋាន* .................................................................... ៣៨


# បញ្ជីតារាង


តារាងទី១- ការព្យាករពីសូចនាករសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ច ................................................. ៧
តារាងទី២- អត្រាកំណើនផ.ស.ស.(ថ្លៃថេរឆ្នាំ២០០០)ដោយសកម្មភាពសេដ្ឋកិច្ច ........................ ៨
តារាងទី៣- ការវិនិយោគមូលធនចាំបាច់ដើម្បីសម្រេចបានកំណើនផ.ស.ស.ដែលបានគ្រោងទុកនិងធនធានដែលអាចមានសម្រាប់ធ្វើហិរញ្ញប្បទានដល់ការវិនិយោគចាំបាច់ ....................... ១០
តារាងទី៤- វិនិយោគមូលធនដែលត្រូវការតាមវិស័យនីមួយៗ ដើម្បីសម្រេចបាននូវគោលដៅនៃកំណើន ផ.ស.ស. ................................................................................. ១១

តារាងទី៥- ចំណុចដៅនៃការកៀរគរធនធានសម្រាប់ការវិនិយោគរបស់វិស័យសាធារណៈឆ្នាំ២០១៥-២០១៧........................................................................................................ ១៤
តារាងទី៦- ការវិភាជតាមវិស័យនិងអនុវិស័យសម្រាប់គម្រូវការវិនិយោគសម្រាប់វិស័យសាធារណៈ ដោយមានមូលដ្ឋានពីការវិភាជតាមវិស័យនិងអនុវិស័យ ចែងនៅក្នុងផ.យ.អ.ជ. ២០១៤-២០១៨ ........................................................................................................ ១៥
តារាងទី៧- ការវិភាជតាមវិស័យនិងអនុវិស័យ សម្រាប់គម្រូវការវិនិយោគវិស័យសាធារណៈ ចែងនៅក្នុងផ.យ.អ.ជ. ២០១៤-២០១៨ និងក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧ ..................... ១៧
តារាងទី៨- សេចក្តីសង្ខេបស្តីពីគម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. ដែលក្រសួង ស្ថាប័នស្នើសុំសម្រាប់ក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧ .............................. ២០
តារាងទី៩- គម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. បែងចែកតាមវិស័យអាទិភាពនៃផ.យ.អ.ជ. ២០១៤-២០១៨ ដែលក្រសួង ស្ថាប័នស្នើសុំ ....................... ២១
តារាងទី១០- បរិមាណខុសគ្នានៃការវិភាជតាមអនុវិស័យផ.យ.អ.ជ.២០១៤-២០១៨ និងការស្នើសុំដោយក្រសួង ស្ថាប័ន ........................................................................................ ៣៣
តារាងទី១១- សេចក្តីសង្ខេបការវិភាជតាមវិស័យក្នុងផ.យ.អ.ជ.២០១៤-២០១៨ និងចំណាយប៉ាន់ស្មានតាមក្រសួង ស្ថាប័ន ...............................................................................៣៤
តារាងទី១២- បញ្ជីគម្រោងបែងចែកតាមក្រសួង ស្ថាប័ន ...................................................... ៤០
តារាងទី១៣- បញ្ជីគម្រោងតាមវិស័យផ.យ.អ.ជ. ២០១៤-២០១៨ និងក្រសួង ស្ថាប័ន ............១១២

# ជំពូកទី១
# សេចក្តីផ្តើម

១- គោលបំណងសំខាន់នៃ*កម្មវិធីវិនិយោគសាធារណៈ(ក.វ.ស.) ៣ឆ្នាំរំកិល២០១៥-២០១៧* គឺធ្វើការបង្ហាញពីទិន្នន័យគម្រោងវិនិយោគដែលមានអាទិភាពខ្ពស់របស់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា ដែលជាគោលនយោបាយមានចែងនៅក្នុង*យុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៣* និងជាផែនទីចង្អុលផ្លូវសម្រាប់ការអនុវត្តគោលនយោបាយដែលមានចែងក្នុង*ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.) ២០១៤-២០១៨*។ *ផ.យ.អ.ជ. ២០១៤-២០១៨* ដែលបានអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិកាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤ ត្រូវបានរៀបចំឡើងដោយមានមូលដ្ឋានពីធាតុចូលរបស់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា។

២- *ក.វ.ស. ៣ឆ្នាំរំកិល* បានដាក់បញ្ចូលគ្នា*គម្រោងកំពុងដំណើរការ* ដែលការអនុវត្តគម្រោងកំពុងបន្តនៅក្នុងដំណាក់កាល ក.វ.ស. និង*គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.* ជាគម្រោងស្នើសុំថ្មីដែលត្រូវនឹងការអនុវត្តក្នុងដំណាក់កាល ក.វ.ស.។

ប្រភពទិន្នន័យសម្រាប់រៀបចំក.វ.ស. រួមមានៈ

(១) ព័ត៌មានស្តីពី*គម្រោងកំពុងដំណើរការ* ក្នុងនោះគម្រោងកំពុងដំណើរការក្នុងក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការ ត្រូវបានផ្តល់ដោយគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងពិនិត្យកែសម្រួលដោយក្រសួង ស្ថាប័នអនុវត្តគម្រោងរបស់រាជរដ្ឋាភិបាលកម្ពុជា។ និង

(២) ព័ត៌មានស្តីពី*គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.* ដែលក្រសួងផែនការបានទទួលពីក្រសួង ស្ថាប័ន ទាំងអស់សម្រាប់រៀបចំ*ក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧*។

## ក- ដំណើរការនៃការងារដឹកនាំដំណើរការសុខដុមនីយកម្ម ការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋនិងហិរញ្ញប្បទានសហប្រតិបត្តិការ

៣- នៅពាក់កណ្តាលឆ្នាំ២០០៩ ***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចបង្កើត*ក្រុមការងារដឹកនាំដំណើរការសុខដុមនីយកម្មការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងហិរញ្ញប្បទានសហប្រតិបត្តិការ* ដើម្បីពង្រឹងការងារសុខដុមនីយកម្ម ការងារផែនការ និងការអនុវត្តជាក់ស្តែង ដែលជាគោលដៅសំខាន់នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២។

៤- បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងធ្វើការពង្រឹងសមត្ថភាពស្ថាប័នដើម្បីភ្ជាប់ទំនាក់ទំនងនៃដំណើរការៈ

(១) កំណត់តម្រូវការជាអាទិភាពសម្រាប់វិនិយោគតាមរយៈកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ដែលរៀបចំឡើងដោយក្រសួងផែនការ។
(២) រៀបចំផែនការយុទ្ធសាស្ត្រថវិកា ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
(៣) រៀបចំទិន្នន័យនៃគម្រោងវិនិយោគមូលធន ដែលកំពុងដំណើរការរបស់នាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ និង
(៤) រៀបចំទិន្នន័យនៃគម្រោងកំពុងដំណើរការនិងការវិភាជធនធានរបស់ដៃគូអភិវឌ្ឍនានា ដោយគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

៥- ក្រុមការងារដឹកនាំដំណើរការសុខដុមនីយកម្ម ការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងហិរញ្ញប្បទានសហប្រតិបត្តិការនេះដឹកនាំដោយក្រសួងផែនការ និងមានសមាជិកមកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ក្រុមការងារបានរៀបចំកិច្ចប្រជុំជាច្រើនដងដើម្បីពិភាក្សានិងកំណត់ទិសដៅការងាររបស់ខ្លួន។ បច្ចុប្បន្ននេះ ក្របខ័ណ្ឌការងាររួមមួយសម្រាប់ការតាមដានត្រួតពិនិត្យការងាររបស់ក្រុមការងារ ត្រូវបានកំណត់ជាសូចនាករសម្រាប់ការតាមដានរួមគ្នា(JMIs)សម្រាប់សកម្មភាពនេះ។ តាមរយៈសូចនាករសម្រាប់ការតាមដានរួមគ្នា ពេលនេះក្រុមការងារកំពុងដំណើរការធ្វើការវិភាគស្ថានភាពលើការងាររបស់ខ្លួន ដើម្បីឈានទៅសម្រេចបានក្របខ័ណ្ឌលទ្ធផលដែលមានចែងនៅក្នុងជំពូកទី៦នៃ*ផ.យ.អ.ជ. ២០១៤-២០១៨*។

## ខ- វិធីសាស្ត្រសម្រាប់ការរៀបចំកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល២០១៥-២០១៧

៦- សម្រាប់ការរៀបចំ*កម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល២០១៥-២០១៧* ក្រសួងផែនការបាននិងកំពុងបន្តធ្វើកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីឈានទៅសម្រេចបាននូវ*សុខដុមនីយកម្ម ការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងហិរញ្ញប្បទានសហប្រតិបត្តិការ និងដើម្បីពង្រឹងយន្តការស្ថាប័ននៃការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព*។

៧- វិធីសាស្ត្រសម្រាប់ការរៀបចំ*កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០១៥-២០១៧* ត្រូវបានអនុវត្តដូចការរៀបចំ*កម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល២០១៤-២០១៦* ។ ដោយវិធីសាស្ត្រថ្មីនេះ រួមមាន *គម្រោងកំពុងដំណើរការ* គឺជាគម្រោងដែលកំពុងត្រូវបានអនុវត្តឬមានកិច្ចសហការនិងការសម្របសម្រួលជាមួយស្ថាប័នរបស់រាជរដ្ឋាភិបាល ហើយការអនុវត្តគម្រោងទាំងនោះនឹងត្រូវបន្តនៅក្នុងអំឡុងពេលនៃក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧ និង*គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. ឬគម្រោងថ្មី* ដែលនឹងត្រូវអនុវត្តក្នុងអំឡុងពេលនៃក.វ.ស. ៣ឆ្នាំរំកិល ២០១៥-២០១៧។ គម្រោងកំពុងដំណើរការ គឺត្រូវបានដាក់បញ្ចូលនូវគម្រោងដែលកំពុងអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាល/សង្គមស៊ីវិលនានា ដោយសហការជាមួយក្រសួង ស្ថាប័នតាមវិស័យពាក់ព័ន្ធ។ ព័ត៌មានសម្រាប់ការរៀបចំក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧ ត្រូវបានធ្វើការ

កែលម្អតាមរយៈកម្រងបញ្ជីសំណួរថ្មីដែលបានចែកចេញជាពីរផ្នែក។ ផ្នែកទី១ គឺការប្រមូលព័ត៌មានស្តីពី*គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.* និងផ្នែកទី២ គឺការប្រមូលព័ត៌មានស្តីពី*គម្រោងកំពុងដំណើរការ*ដែលបញ្ជីសំណួរ ក.វ.ស. ៣ឆ្នាំរំកិលថ្មីមានបង្ហាញក្នុងឧបសម្ព័ន្ធ១។

៨- សម្រាប់ការរៀបចំក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧ និងតាមសំណើរបស់ក្រសួងផែនការ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា បានផ្ញើមកក្រសួងផែនការនូវព័ត៌មានស្តីពី*ការចំណាយជំនួយអភិវឌ្ឍផ្លូវការទៅតាមគម្រោងនិងក្រសួង ស្ថាប័នដែលរាយការណ៍ដោយដៃគូអភិវឌ្ឍជារៀងរាល់ឆ្នាំ* ។ គម្រោងកំពុងដំណើរការទាំងអស់ដែលរាយការណ៍ដោយដៃគូអភិវឌ្ឍគឺជាបណ្តាគម្រោងដែលកំពុងអនុវត្តដោយៈ (១) ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល (២) ដៃគូអភិវឌ្ឍ និង(៣) សង្គមស៊ីវិល ដោយមានការគាំទ្រផ្តល់ថវិកាពីដៃគូអភិវឌ្ឍ។

៩- ប្រភពទិន្នន័យសំខាន់សម្រាប់ការរៀបចំក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧ គឺក្រសួងផែនការបានទទួលពីគ្រប់ក្រសួង ស្ថាប័ន។ តាមរយៈការអនុវត្តជាក់ស្តែង យើងទទួលស្គាល់ថាទិន្នន័យស្តីពីគម្រោងកំពុងដំណើរការដែលក្រសួង ស្ថាប័នផ្ញើមកក្រសួងផែនការ មានដាក់បញ្ចូលនូវគម្រោងកំពុងដំណើរការមួយចំនួន ដែលដៃគូអភិវឌ្ឍបានរាយការណ៍ជូនគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា។ ប៉ុន្តែដើម្បីធានាបាននូវការកត់ត្រាច្បាស់លាស់នូវចំនួនគម្រោងកំពុងដំណើរការដែលកំពុងអនុវត្តដោយមានឬពុំមានកិច្ចសហការជាមួយក្រសួង ស្ថាប័ននីមួយៗ និងដើម្បីជួយសម្រួលដល់ការរៀបចំទិន្នន័យគម្រោងកំពុងដំណើរការរបស់ក្រសួង ស្ថាប័ន ក្រសួងផែនការបានផ្ញើបញ្ជីគម្រោងកំពុងដំណើរការដែលបានទទួលពីគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ទៅគ្រប់ក្រសួង ស្ថាប័ន ដើម្បីពិនិត្យនិងដាក់បញ្ចូលសម្រាប់ការរៀបចំក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧។

១០- ចំពោះ*គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.(គម្រោងថ្មី)* ដែលនឹងត្រូវអនុវត្តក្នុងអំឡុងឆ្នាំ២០១៥-២០១៧ ក្រសួងផែនការបានផ្តល់សេចក្តីណែនាំនិងពន្យល់ដោយផ្ទាល់ដល់គ្រប់ក្រសួង ស្ថាប័ន បន្ថែមពីលើការពន្យល់តាមរយៈសិក្ខាសាលាជាតិនាពេលកន្លងមក ដើម្បីធានាថាក្នុងការស្នើសុំ*គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.* ក្រសួង ស្ថាប័នទាំងអស់បានៈ

(១) គិតច្បាស់លាស់ពីសារៈសំខាន់នៃគម្រោងទាំងនោះ ក្នុងការគាំទ្រដល់គោលដៅអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចរបស់រាជរដ្ឋាភិបាល ដើម្បីឈានទៅសម្រេចបាននូវគោលនយោបាយជាអាទិភាពនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ ព្រមទាំងផែនការរបស់ក្រសួង ស្ថាប័ន ដែលមានចែងនៅក្នុង*ផ.យ.អ.ជ. ២០១៤-២០១៨*។

(២) ពិនិត្យច្បាស់លាស់ការវិភាជតាមវិស័យអាទិភាព ដែលមានចែងនៅក្នុង*ផ.យ.អ.ជ. ២០១៤-២០១៨*។

(៣) ពិនិត្យលទ្ធផលនៃកិច្ចពិភាក្សារវាងមន្ត្រីរបស់ក្រសួង ស្ថាប័ននីមួយៗ និងនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការរៀបចំ*ផែនការយុទ្ធសាស្ត្រថវិការយៈពេលវែងសម្រាប់ក្រសួង ស្ថាប័នរបស់ខ្លួន។*

(៤) ពិនិត្យច្បាស់លាស់ពីប្រភពធនធានជាសក្តានុពលក្នុងការផ្តល់ហិរញ្ញប្បទានដល់គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.។

(៥) កំណត់*លំដាប់អាទិភាព* ចំពោះគម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. នីមួយៗដែលក្រសួង ស្ថាប័នបានផ្ញើមកក្រសួងផែនការ។ នាពេលសិក្ខាសាលាជាតិស្តីពីការផ្សព្វផ្សាយដំណើរការនៃការរៀបចំ*ក.វ.ស. ៣ឆ្នាំរំកិល២០១១-២០១៣* ក្រសួងផែនការបានបញ្ជាក់ច្បាស់ថា៖

- អាទិភាពគម្រោងមិនអាចមានលំដាប់ដូចគ្នានៅក្នុងក្រសួង ស្ថាប័នតែមួយ
- ចំពោះករណីគម្រោងអភិក្រមគ្រប់គ្រងទូទាំងវិស័យឬកម្មវិធីធំ ត្រូវផ្តល់ព័ត៌មានស្តីពីផ្នែកទាំងឡាយនៃគម្រោងដែលអាចទទួលបានហិរញ្ញប្បទានជាគម្រោង ព្រមទាំងគម្រោងតាមផ្នែកផ្សេងៗទៀតដែលត្រូវការនូវការកំណត់លំដាប់អាទិភាពដោយផ្អែកលើរយៈពេលនៃការអនុវត្តសកម្មភាពអភិក្រមគ្រប់គ្រងទូទាំងវិស័យឬសកម្មភាពដែលបានកំណត់របស់កម្មវិធីធំៗ
- ក្រសួងផែនការនឹងធ្វើការផ្តល់លេខគម្រោងដល់គ្រប់គម្រោង*ក.វ.ស. ៣ឆ្នាំរំកិល* ទាំងអស់ដែលថ្នាក់ដឹកនាំក្រសួង ស្ថាប័នបានកំណត់អាទិភាពនិងផ្ញើមកក្រសួងផែនការ។

១១- ក្រសួងផែនការធ្វើការវិភាជថវិកាសម្រាប់*ក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧* ដោយមានមូលដ្ឋាននៃលក្ខណវិនិច្ឆ័យ ដូចខាងក្រោម៖

- ការវិភាជសរុបសម្រាប់វិស័យដល់*គម្រោងកំពុងដំណើរការ* និង*គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.* ត្រូវមានសង្គតិភាពជាមួយការវិភាជតាមវិស័យដែលមានចែងនៅក្នុង*ផ.យ.អ.ជ. ២០១៤-២០១៨*។
- អាទិភាពនៃការវិភាជថវិកាដែលមានដល់បណ្តាគម្រោងកំពុងដំណើរការ ដើម្បីបន្តការអនុវត្តនិងបញ្ចប់ការអនុវត្ត។
- ថវិកាដែលនៅសល់នឹងត្រូវធ្វើការវិភាជដល់គម្រោងសម្រាប់អនុវត្ត*ផ.យ.អ.ជ.* ដោយផ្អែកលើ៖
  - អាទិភាពនៃគម្រោងដែលកំណត់ដោយក្រសួង ស្ថាប័ន
  - គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. ទាំងនោះសម្រាប់អនុវត្តយុទ្ធសាស្ត្រតាមវិស័យរបស់ក្រសួង ស្ថាប័ន ដើម្បីអនុវត្តគោលនយោបាយអាទិភាពនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងអាទិភាពដែលមានចែងនៅក្នុង*ផ.យ.អ.ជ. ២០១៤-២០១៨*

- ព័ត៌មានដែលក្រសួង ស្ថាប័ន បានផ្ញើមកក្រសួងផែនការស្តីពីស្ថានភាពសក្តានុពលក្នុងការសន្យាផ្តល់ហិរញ្ញប្បទានដល់គម្រោងសម្រាប់អនុវត្ត*ផ.យ.អ.ជ.*
- កិច្ចពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងកែសម្រួលឡើងវិញនូវការសន្យាផ្តល់ថវិកាពីកញ្ចប់ថវិកាជាតិ និងលទ្ធផលនៃកិច្ចពិភាក្សារវាងក្រសួងស្ថាប័ននិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការរៀបចំ*ផែនការយុទ្ធសាស្ត្រថវិកា* សម្រាប់ក្រសួង ស្ថាប័ននីមួយៗ។

១២- ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃ*ក.វ.ស. ៣ឆ្នាំរំកិល* ក្រសួងផែនការបានរៀបចំកែសម្រួលឡើងវិញនូវប្រព័ន្ធទិន្នន័យរបស់*ក.វ.ស. ៣ឆ្នាំរំកិល* និងបញ្ជីសំណួរ រួចផ្ញើទៅក្រសួង ស្ថាប័នទាំងអស់សម្រាប់ឲ្យមន្ត្រីរបស់ក្រសួង ស្ថាប័នទាំងនោះបំពេញតាមប្រព័ន្ធកុំព្យូទ័រ និងផ្ញើត្រឡប់មកក្រសួងផែនការវិញ។

១៣- នៅក្នុង*ក.វ.ស. ៣ឆ្នាំរំកិល* ឆ្នាំមុនៗ (មុន*ក.វ.ស. ៣ឆ្នាំរំកិល២០១១-២០១៣*) ក្រសួងផែនការបានរៀបចំរបាយការណ៍វាយតម្លៃលើស្ថានភាពនៃការអនុវត្តគម្រោង *ក.វ.ស. ៣ឆ្នាំរំកិល* នៅឆ្នាំមុន។ ប៉ុន្តែបច្ចុប្បន្ននេះ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជាបានរៀបចំរបាយការណ៍ស្តីពីប្រសិទ្ធភាពជំនួយ ដែលរួមមានការវិភាគលើការបន្សុំធនធានដែលបានផ្តល់ជាមួយនឹងការវិភាជតាមវិស័យមានចែងនៅក្នុង*ផ.យ.អ.ជ.*។ ដូច្នេះ *ក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧* ក៏បន្តមិនដាក់បញ្ចូលនូវរបាយការណ៍វាយតម្លៃលើស្ថានភាពនៃការអនុវត្តគម្រោង*ក.វ.ស. ៣ឆ្នាំរំកិល* នៅឆ្នាំមុនទៀតដែរ។

១៤- បន្ទាប់ពីសេចក្តីផ្តើមនៃ*ក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧* នឹងមានបង្ហាញអំពីព័ត៌មានស្តីពីទស្សនវិស័យសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៥-២០១៧ ក្នុងជំពូកទី២។ ជំពូកទី៣ បង្ហាញអំពីព័ត៌មានស្តីពី*ក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧* និងជំពូកទី៤ បង្ហាញអំពីសេចក្តីសន្និដ្ឋាន។

# ជំពូកទី២
# ទស្សនវិស័យសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៥-២០១៧

## ក- ស្ថានភាពទូទៅនៃកំណើនផលិតផលក្នុងស្រុកសរុប២០១៥-២០១៧

១៥- នេះជាឆ្នាំទី៦នៃវិបត្តិហិរញ្ញវត្ថុសកលលោកនិងការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចសកលលោកដែលចាប់ផ្តើមក្នុងឆ្នាំ២០០៩ នៅក្នុងប្រទេសអភិវឌ្ឍជាច្រើន បានជះឥទ្ធិពលនិងប៉ះពាល់ដល់វិស័យសំខាន់ៗមួយចំនួននៃសេដ្ឋកិច្ចរបស់កម្ពុជា ដែលធ្វើឲ្យកំណើនផលិតផលក្នុងស្រុកសរុប(ផ.ស.ស.) បានធ្លាក់ចុះពី៦,៧ភាគរយក្នុងឆ្នាំ២០០៨ មកនៅត្រឹមតែ0,១ភាគរយក្នុងឆ្នាំ២០០៩។ នៅក្នុងអំឡុងពេលវិបត្តិនេះ វិស័យកសិកម្មនិងសេវានៅរក្សាកំណើនបានយ៉ាងល្អដែលបានជួយបំពេញនូវការធ្លាក់ចុះក្នុងវិស័យមួយចំនួនទៀត ជាពិសេសវិស័យឧស្សាហកម្ម និងវិស័យសេវាកម្មមានការកើនឡើងតិចតួចប្រមាណ២,៣ភាគរយ។ ដោយសាររាជរដ្ឋាភិបាលបានអនុវត្តគោលនយោបាយច្បាស់លាស់ បានធ្វើឲ្យកំណើនផ.ស.ស.កើនឡើងខ្ពស់វិញ គឺ៦ភាគរយនៅឆ្នាំ២០១០ ៧,១ភាគរយក្នុងឆ្នាំ២០១១ ៧,៣ភាគរយ ក្នុងឆ្នាំ២០១២ និងកើនដល់៧,៤ភាគរយក្នុងឆ្នាំ២០១៣។ ការព្យាករអំពីសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗសម្រាប់ឆ្នាំ២០១៤-២០១៧ មានបង្ហាញក្នុងតារាងទី១។

១៦- នាបណ្តាឆ្នាំ២០០៩ ២០១០ និងឆ្នាំ២០១១ រាជរដ្ឋាភិបាលបានប្រើប្រាស់ធនធានបម្រុងសម្រាប់ធនាគារពាណិជ្ជនិងបង្កើនចំណាយរដ្ឋលើវិស័យហេដ្ឋារចនាសម្ព័ន្ធ ដើម្បីជំរុញកំណើនតម្រូវការ ដូចជាការបង្កើតហេដ្ឋារចនាសម្ព័ន្ធនិងទំនុកចិត្តរបស់ប្រជាជន ជាពិសេស កម្លាំងពលកម្មក្នុងវិស័យវាយនភណ្ឌកាត់ដេរដែលកំពុងបាត់បង់ការងារ។ ក៏ប៉ុន្តែការគាំទ្ររបៀបនេះអាចជួយស្រោចស្រង់បានជាបណ្តោះអាសន្នតែប៉ុណ្ណោះ ឬអាចនិយាយបានថា សម្រាប់តែទំហំសេដ្ឋកិច្ចតូចៗដែលពឹងផ្អែកជាសំខាន់ទៅលើទីផ្សារបរទេសសម្រាប់ផលិតផលរបស់ខ្លួន។ ទាំងអស់ដូចបានបង្ហាញខាងលើនេះបញ្ជាក់ច្បាស់ថា បរិមាណផលិតផលដែលមានចំនួនកំណត់សម្រាប់ផ្គត់ផ្គង់នឹងបន្តក្នុងរយៈពេលខ្លីនិងមធ្យម ដែលជាឧបសគ្គរារាំងដល់ការកាន់កាប់សេដ្ឋកិច្ច។ ដើម្បីជម្នះបាននូវឧបសគ្គ រាជរដ្ឋាភិបាលកំពុងពង្រីកវិសាលភាពនិងពង្រឹងគុណភាពផលិតផលនិងសេវាកម្មរបស់ខ្លួនបន្ថែមទៀតសម្រាប់ពង្រីកនិងពង្រឹងសេដ្ឋកិច្ច។

**តារាងទី១ : ការព្យាករអំពីសូចនាករសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ច**

| សូចនាករសេដ្ឋកិច្ច | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|
| ផ.ស.ស. (ថ្លៃថេរឆ្នាំ២០០០-គិតជាពាន់លានរៀល) | ៦៧ ៧៧២ | ៧៤ ៤៤៤ | ៨២ ១៧៤ | ៩០ ៤១៦ |
| ផ.ស.ស. (ថ្លៃថេរឆ្នាំ២០០០-គិតជាលានដុល្លារអាមេរិក) | ១៦ ៧៣៤ | ១៨ ៨៣១ | ២០ ២៩០ | ២២ ០៥៣ |
| ផ.ស.ស. សម្រាប់ប្រជាជនម្នាក់ (ដុល្លារអាមេរិក) | ១ ០៤៣ | ១ ១៣០ | ១ ២២៥ | ១ ៣៣៥ |
| **អត្រាកំណើនពិត នៃផ.ស.ស. (%)** | ៧,០ | ៧,០ | ៧,០ | ៦,៩ |
| | | | | |
| អតិផរណា (ការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ - គិតជាភាគរយ) | ៣,៥ | ៣,៥ | ៣,៥ | ៣,៥ |
| | | | | |
| **ការវិនិយោគសរុប (% ផ.ស.ស.)** | ២៦,៤ | ២៦,៩ | ២៦,៩ | ២៧,១ |
| ការវិនិយោគសាធារណៈ (%ផ.ស.ស.) | ៧,៦ | ៨,០ | ៨,០ | ៨,១ |
| ការវិនិយោគឯកជន (%ផ.ស.ស.) | ១៨,៨ | ១៨,៨ | ១៨,៩ | ១៩,០ |
| | | | | |
| **ចំណូលថវិកាសរុប (% ផ.ស.ស.)** | ១៥,៧ | ១៦,១ | ១៦,៥ | ១៦,៩ |
| **ចំណាយថវិកាសរុប (% ផ.ស.ស.)** | ១៩,៨ | ២០,៦ | ២០,៧ | ២០,៧ |

មានមូលដ្ឋានលើអត្រាប្តូរប្រាក់៤ ១០០រៀល = ១ដុល្លារអាមេរិក

*ប្រភព : វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (គិតដល់ខែកក្កដា ឆ្នាំ២០១៤)*

១៧- រាជរដ្ឋាភិបាលកម្ពុជាមានផែនការច្បាស់លាស់សម្រាប់ការរៀបចំផ.យ.អ.ជ. ២០១៤-២០១៨ គឺវិស័យហេដ្ឋារចនាសម្ព័ន្ធ វិស័យផ្សេងៗទៀត និងបច្ចេកវិទ្យា នឹងត្រូវបានពង្រឹងនិងពង្រីកបន្ថែមដែលជាជំនួយដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ដូចជាសហគ្រាសធុនតូចនិងមធ្យម កែច្នៃចំណីអាហារ និងឧស្សាហកម្មរ៉ែ។

## ខ- អត្រាកំណើនផ.ស.ស. ពិត(ថ្លៃថេរឆ្នាំ២០០០) តាមសកម្មភាពសេដ្ឋកិច្ច

១៨- តាមរយៈបទពិសោធដែលទទួលបានពីការធ្លាក់ចុះនៃសេដ្ឋកិច្ចក្នុងឆ្នាំ២០០៩ និងកិច្ចខំឥតស្រាកស្រាន្តរបស់រាជរដ្ឋាភិបាល គឺយើងសម្រេចបានកំណើនពីវិស័យឧស្សាហកម្មកើនឡើងពីរខ្ទង់នៅឆ្នាំ២០១០និងឆ្នាំ២០១១ និងវិស័យសំណង់ក៏មានកំណើនដូចឧស្សាហកម្មដែរ ដែលជាមូលដ្ឋានដែលជួយស្តារនូវកំណើនផ.ស.ស. ឡើងវិញនៅឆ្នាំ២០១០និងឆ្នាំ២០១១ បន្ទាប់ពីបានធ្លាក់ចុះនៅឆ្នាំ២០០៩។ ការព្យាករអំពីអត្រាកំណើនផ.ស.ស. ដោយសកម្មភាពសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៤-២០១៧ មានបង្ហាញក្នុងតារាងទី២។

## តារាងទី២ : អត្រាកំណើនផ.ស.ស. (ថ្លៃថេរឆ្នាំ២០០០) តាមសកម្មភាពសេដ្ឋកិច្ច

| | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|
| **កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | **២,៦%** | **៣,៨%** | **៣,៧%** | **៣,៧%** |
| ដំណាំ | ២,៣% | ៣,៦% | ៣,៥% | ៣,៤% |
| បសុសត្វនិងបសុបក្សី | ១,២% | ៤,៣% | ៤,៣% | ៤,៤% |
| ជលផល | ៥,៧% | ៤,៦% | ៤,៦% | ៤,៧% |
| ផលព្រៃឈើ | -៦,០% | ០,១% | ០,១% | ០,១% |
| **ឧស្សាហកម្ម** | **៩,៦%** | **៩,០%** | **៨,៩%** | **៨,៦%** |
| រ៉ែ | ២០,៧% | ១៥,៣% | ១២,៩% | ១៣,០% |
| កម្មន្តសាល | ៦,៨% | ៧,៧% | ៧,៧% | ៧,៧% |
| អាហារ ភេសជ្ជៈ និងថ្នាំជក់ | ៦,៩% | ៥,០% | ៤,៧% | ៤,៨% |
| វាយនភណ្ឌ សម្លៀកបំពាក់ និងស្បែកជើង | ៦,៦% | ៨,៣% | ៨,៣% | ៨,២% |
| ឈើ ក្រដាស និងការបោះពុម្ព | ៦,៩% | ៥,២% | ៥,០% | ៥,១% |
| កម្មន្តសាលកៅស៊ូ | ៨,០% | ៥,៨% | ៥,៥% | ៥,៦% |
| កម្មន្តសាលផ្សេងៗទៀត | ៨,៥% | ៦,៣% | ៦,៣% | ៦,៩% |
| អគ្គិសនី ឧស្ម័ន និងទឹក | ៧,៩% | ៧,០% | ៦,៤% | ៦,៥% |
| សំណង់ | ១៨,៦% | ១២,៨% | ១២,៦% | ១១,២% |
| **សេវា** | **៧,៥%** | **៧,១%** | **៧,០%** | **៧,១%** |
| ពាណិជ្ជកម្ម | ៥,៥% | ៦,០% | ៦,០% | ៦,១% |
| សណ្ឋាគារនិងភោជនីយដ្ឋាន | ៦,៩% | ៩,៧% | ១០,១% | ៩,៩% |
| ដឹកជញ្ជូននិងទូរគមនាគមន៍ | ៦,៥% | ៦,៧% | ៦,៦% | ៦,៨% |
| ហិរញ្ញវត្ថុ | ៨,៦% | ៨,៣% | ៨,៣% | ៨,៤% |
| រដ្ឋបាលសាធារណៈ | ៣,៦% | ៣,៤% | ៣,១% | ៣,២% |
| អចលនវត្ថុនិងធុរកិច្ច | ១០,៤% | ៨,៥% | ៨,១% | ៨,២% |
| សេវាផ្សេងៗទៀត | ៨,៨% | ៦,០% | ៥,៩% | ៥,៩% |
| | | | | |
| ពន្ធលើផលិតផលដកឧបត្ថម្ភធន | ៨,១% | ៧,៧% | ៨,២% | ៨,៣% |
| ដក : ឧបត្ថម្ភធន | ៥,៩% | ៩,៦% | ៧,២% | ៧,២% |
| ដក : បន្ទុកលើសេវាហិរញ្ញវត្ថុ | ៧,៩% | ១៥,៩% | ៨,៣% | ៨,៤% |
| **សរុប ផលិតផលក្នុងស្រុកសរុប( សរុប ផ.ស.ស.)** | **៧,០%** | **៧,០%** | **៧,០%** | **៦,៩%** |

*ប្រភព : វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

## គ- ការវិនិយោគដែលចាំបាច់ដើម្បីសម្រេចបាននូវកំណើនផ.ស.ស.ដែលបានគ្រោងទុក

១៩- គំរូនៃសេដ្ឋកិច្ចវិទ្យាធ្លាប់ប្រើដើម្បីធ្វើការព្យាករអំពីសេដ្ឋកិច្ចសម្រាប់រយៈពេល៥ឆ្នាំ ពីឆ្នាំ ២០០៩ដល់២០១៣ ក៏អាចត្រូវបានប្រើប្រាស់ដើម្បីធ្វើការព្យាករពីការវិនិយោគសរុបដែលចាំបាច់ក្នុងការធ្វើឲ្យសម្រេចបាននូវ*កំណើនផ.ស.ស.* ដូចដែលបានគ្រោងទុក និងការបែងចែកនៃការវិនិយោគសរុបទៅតាមវិស័យសេដ្ឋកិច្ច។ ថ្វីបើភាពមានកម្រិតខ្លះពីគំរូនៃសេដ្ឋកិច្ចវិទ្យាក៏ដោយ ក៏លទ្ធផលនៃការវិភាគបង្ហាញថា ទឹកប្រាក់នៃការវិនិយោគសរុបចំនួន៦៦ ៦៥០,៨ពាន់លានរៀល (១៦,៤ពាន់លានដុល្លារអាមេរិក) គឺជាតម្រូវការដើម្បីសម្រេចបាននូវកំណើន*ផ.ស.ស.* ដែលបានគ្រោងទុកសម្រាប់ដំណាក់កាលនៃ*ក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧* និងដែលតម្រូវការសម្រាប់ឆ្នាំនីមួយៗប្រមាណ២២ ២១៦,៩ពាន់លានរៀល(៥,៥ពាន់លានដុល្លារអាមេរិក)។

២០- ប្រភពផ្តល់ហិរញ្ញប្បទានដល់វិនិយោគសរុបចំនួន៦៦ ៦៥០,៨ពាន់លានរៀល ក្នុងអំឡុងពេល *ក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧* (មានបង្ហាញនៅក្នុងតារាងទី៣)៖

- វិនិយោគមូលធនរបស់វិស័យឯកជននឹងមានប្រមាណ៤៦ ៧៨២,១ពាន់លានរៀល (១១,៥ពាន់លានដុល្លារអាមេរិក) សមមូលនឹង៧០ភាគរយនៃវិនិយោគមូលធនសរុប
- វិនិយោគមូលធនវិស័យសាធារណៈនឹងមានប្រមាណ១៩ ៨៦៨,៧ពាន់លានរៀល (៤,៩ពាន់លានដុល្លារអាមេរិក) សមមូលនឹង៣០ភាគរយនៃវិនិយោគមូលធនសរុប។

២១- ប្រភពធនធានសម្រាប់តម្រូវការវិនិយោគពីក្នុងស្រុកនិងពីក្រៅប្រទេសសម្រាប់ផ្តល់ហិរញ្ញប្បទានដល់តម្រូវការវិនិយោគសរុប៦៦ ៦៥០,៨ពាន់លានរៀល ក្នុងអំឡុងពេល*ក.វ.ស. ៣ឆ្នាំរំកិល ២០១៥-២០១៧*៖

- ៣២ ៩៤១ពាន់លានរៀល(៨ពាន់លានដុល្លារអាមេរិក) សមមូលនឹង៤៩,៥ភាគរយ នៃវិនិយោគមូលធនសរុបនឹងត្រូវបានទទួលពីប្រភពក្នុងស្រុក
- ៣៣ ៧០៩,៨ពាន់លានរៀល(៨,២ពាន់លានដុល្លារអាមេរិក) សមមូលនឹង៥០,៥ភាគរយនៃវិនិយោគមូលធនសរុបនឹងត្រូវបានទទួលពីប្រភពក្រៅប្រទេស។

**តារាងទី៣ : ការវិនិយោគចាំបាច់ដើម្បីសម្រេចបានកំណើនផ.ស.ស. ដែលបានគ្រោងទុក និងធនធានដែលអាច មានសម្រាប់ធ្វើហិរញ្ញប្បទានដល់ការវិនិយោគចាំបាច់**

(គិតជា ពាន់លានរៀល)

| ប្រភពហិរញ្ញប្បទាន | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | សរុប ២០១៥-១៧ |
|---|---|---|---|---|---|
| **វិនិយោគមូលធន សរុប** | **១៧ ៩១០,៥** | **១៩ ៩៥៥,២** | **២២ ១៤០,៩** | **២៤ ៥១៤,៧** | **៦៦ ៦៥០,៨** |
| • **វិនិយោគមូលធនវិស័យសាធារណៈ** | **៥ ១៥០,៩** | **៥ ៩៦៥,២** | **៦ ៦១៩,៨** | **៧ ៧៩២,៧** | **១៩ ៨៦៨,៧** |
| ➢ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ១ ២៦៦,០ | ១ ៤៦៦,១ | ១ ៦២៤,៨ | ១ ៧៩២,៤ | ៤ ៨៨៣,៤ |
| ➢ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស[1] | ៣ ៨៨៤,៩ | ៤ ៤៩៩,០ | ៤ ៩៨៦,០ | ៥ ៥០០,៣ | ១៤ ៩៨៥,៣ |
| • **វិនិយោគមូលធនវិស័យឯកជន** | **១២ ៧៥៩,៦** | **១៤ ០៣០,១** | **១៥ ៥៣០,១** | **១៧ ២២២,០** | **៤៦ ៧៨២,១** |
| ➢ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ៧ ៦៩៧,១ | ៨ ៤៦៥,៧ | ៩ ៣២១,០ | ១០ ២៧១,០ | ២៨ ០៥៧,៦ |
| ➢ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស[1] | ៥ ០៦២,៥ | ៥ ៥៦៤,៤ | ៦ ២០៩,១ | ៦ ៩៥១,០ | ១៨ ៧២៤,៥ |
| **វិនិយោគមូលធនសរុប** | **១៧ ៩១០,៥** | **១៩ ៩៩៥,២** | **២២ ១៤០,៩** | **២៤ ៥១៤,៧** | **៦៦ ៦៥០,៨** |
| • **វិនិយោគមូលធនវិស័យសាធារណៈ** | ៥ ១៥០,៩ | ៥ ៩៦៥,២ | ៦ ៦១០,៨ | ៧ ២៩២,៧ | ១៩ ៨៦៨,៧ |
| • **វិនិយោគមូលធនវិស័យឯកជន** | ១២ ៧៥៩,៦ | ១៤ ០៣០,១ | ១៥ ៥៣០,១ | ១៧ ២២២,០ | ៤៦ ៧៨២,១ |
| **វិនិយោគមូលធនសរុប** | **១៧ ៩១០,៥** | **១៩ ៩៩៥,២** | **២២ ១៤០,៩** | **២៤ ៥១៤,៧** | **៦៦ ៦៥០,៨** |
| • ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ៨ ៩៦៣,១ | ៩ ៩៣១,៨ | ១០ ៩៤៥,៨ | ១២ ០៦៣,៤ | ៣២ ៩៤១,០ |
| • ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស[1] | ៨ ៩៤៧,៤ | ១០ ០៦៣,៤ | ១១ ១៩៥,១ | ១២ ៤៥១,៣ | ៣៣ ៧០៩,៨ |
| **វិនិយោគមូលធនវិស័យសាធារណៈ** | **៥ ១៥០,៩** | **៥ ៩៦៥,២** | **៦ ៦១៩,៨** | **៧ ៧៩២,៧** | **១៩ ៨៦៨,៧** |
| • ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ១ ២៦៦,០ | ១ ៤៦៦,១ | ១ ៦២៤,៨ | ១ ៧៩២,៤ | ៤ ៨៨៣,៤ |
| • ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស[1] | ៣ ៨៨៤,៩ | ៤ ៤៩៩,០ | ៤ ៩៨៦,០ | ៥ ៥០០,៣ | ១៤ ៩៨៥,៣ |

១ វិនិយោគមូលធន មិនរាប់បញ្ចូលជំនួយបច្ចេកទេស

*ប្រភព: ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

២២- ការបែងចែកលម្អិតនៃការវិនិយោគចាំបាច់ដើម្បីសម្រេចបាននូវកំណើនផ.ស.ស. សរុប ដែលបានគ្រោងទុកតាមរយៈវិស័យសេដ្ឋកិច្ច ត្រូវបានបង្ហាញក្នុងតារាងទី៤។ ដើម្បីសម្រេចបានអត្រាកំណើនផ.ស.ស.សរុប ដែលបានគ្រោងទុកតាមវិស័យ ការវិនិយោគក្នុងក្រុមវិស័យសំខាន់ៗ រួមមានដូចខាងក្រោម៖

- វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវការទុនវិនិយោគចំនួន៩ ៩៣៨,៨ពាន់លានរៀល(២,៤ពាន់លានដុល្លារអាមេរិក) ដែលផ្តោតជាសំខាន់លើដំណាំស្រូវជាពិសេស

ដើម្បីអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល សម្រាប់ការបង្កើនការនាំអង្ករទៅទីផ្សារអន្តរជាតិសម្រាប់រយៈពេលក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧

- វិស័យឧស្សាហកម្មទូទៅ រួមមានការរុករករ៉ែ កម្មន្តសាល អគ្គិសនី ឧស្ម័ន ទឹក និងសំណង់នឹងត្រូវការទុនវិនិយោគចំនួន៣៣ ៩៨៦,៤ពាន់លានរៀល (៨,៣ពាន់លានដុល្លារអាមេរិក) សម្រាប់រយៈពេលក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧។ នៅក្នុងក្រុមនេះ អនុវិស័យកម្មន្តសាល (វាយនភណ្ឌ សម្លៀកបំពាក់ និងស្បែកជើង) នឹងត្រូវការចំណែកធំជាងគេនៃការវិនិយោគ គឺមានចំនួនប្រមាណ១៣ ៦១៥,២ពាន់លានរៀល(៣,៣ពាន់លានដុល្លារអាមេរិក) និងអនុវិស័យសំណង់ ត្រូវការចំណែកធំនៃការវិនិយោគ គឺមានចំនួន១៣ ២១៩,២ពាន់លានរៀល(៣,២ពាន់លានដុល្លារអាមេរិក) ហើយអនុវិស័យអគ្គិសនីឧស្ម័ននិងទឹក ត្រូវការទុនវិនិយោគចំនួនប្រមាណ៤ ៥៨០,៦ពាន់លានរៀល(១,១ពាន់លានដុល្លារអាមេរិក)
- វិស័យសេវា រួមមាន ពាណិជ្ជកម្ម សណ្ឋាគារ និងភោជនីយដ្ឋាន(ទេសចរណ៍) ដឹកជញ្ជូន និងទូរគមនាគមន៍ ហិរញ្ញវត្ថុ រដ្ឋបាលសាធារណៈ និងអចលនទ្រព្យត្រូវការទុនវិនិយោគចំនួន២២ ៧២៥,៦ពាន់លានរៀល(៥,៦ពាន់លានដុល្លារអាមេរិក)។

**តារាងទី៤ : វិនិយោគមូលធនដែលត្រូវការតាមវិស័យនីមួយៗដើម្បីសម្រេចបាននូវគោលដៅកំណើនផ.ស.ស.**

(គិតជាពាន់លានរៀល)

| | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | សរុប ២០១៥-១៧ |
|---|---|---|---|---|---|
| **កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | ២ ៦១៥,៦ | ៣ ០៩១,៨ | ៣ ៣០៩,៣ | ៣ ៥៣៧,៧ | ៩ ៩៣៨,៨ |
| ដំណាំ | ២ ១៦៨,៩ | ២ ៣២៤,៧ | ២ ៤៨៧,៥ | ២ ៦៥៧,១ | ៧ ៤៦៩,៣ |
| បសុសត្វនិងបសុបក្សី | ១៣៣,៩ | ២១៧,០ | ២៣៣,៨ | ២៥២,០ | ៧០២,៨ |
| ជលផល | ១៨០,៦ | ៤១៣,៤ | ៤៤៦,៨ | ៤៨២,៧ | ១ ៣៤២,៩ |
| ផលព្រៃឈើ | ១៣២,២ | ១៣៦,៧ | ១៤១,៣ | ១៤៦,០ | ៤២៣,៩ |
| **ឧស្សាហកម្ម** | ៩ ០៤០,៧ | ១០ ០២៧,៥ | ១១ ២៨១,២ | ១២ ៦៧៧,៧ | ៣៣ ៩៨៦,៤ |
| រ៉ែ | ៦១៦,២ | ៧៣១,៥ | ៨៥០,៥ | ៩៨៨,៨ | ២ ៥៧០,៨ |
| កម្មន្តសាល | ៣ ៨៩៧,៤ | ៤ ១១២,៣ | ៤ ៥១០,៣ | ៤ ៩៩៣,៣ | ១៣ ៦១៥,៨ |
| អាហារ ភេសជ្ជៈ និងថ្នាំជក់ | ៣៦៧,៤ | ៣៩៧,៣ | ៤២៨,៤ | ៤៦២,០ | ១ ២៨៧,៨ |
| វាយនភណ្ឌ សម្លៀកបំពាក់ និងស្បែកជើង | ១ ៥៥៦,១ | ១ ៥៥៥,៩ | ១ ៧២២,២ | ១ ៩៤១,៧ | ១៣ ៦១៥,៨ |
| ឈើ ក្រដាស និងការបោះពុម្ព | ៩៥,៥ | ១០៣,៥ | ១១១,៩ | ១២១,០ | ៣៣៦,៤ |
| កម្មន្តសាលកៅស៊ូ | ១៤៤,៦ | ១៥៧,៧ | ១៧១,៣ | ១៨៦,០ | ៥១៥,០ |
| កម្មន្តសាលផ្សេងៗទៀត | ១ ៧៣៣,៧ | ១ ៨៩៧,៩ | ២ ០៧៦,៤ | ២ ២៨២,៥ | ៦ ២៥៦,៨ |
| អគ្គិសនី ឧស្ម័ន និងទឹក | ១ ២៦០,៩ | ១ ៣៩០,២ | ១ ៥២២,៧ | ១ ៦៧៧,៧ | ៤ ៥៨០,៨ |
| សំណង់ | ៣ ២៦៦,២ | ៣ ៧៩៣,៥ | ៤ ៣៩៧,៨ | ៥ ០២៧,៩ | ១៣ ២១៩,២ |

| | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | សរុប ២០១៥-១៧ |
|---|---|---|---|---|---|
| សេវា | ៦ ២៥៤,២ | ៦ ៨៧៥,៩ | ៧ ៥៥០,៤ | ៨ ២៩៩,៣ | ២២ ៧២៥,៦ |
| ពាណិជ្ជកម្ម | ១ ១០៥,៧ | ១ ២០៦,៧ | ១ ៣១៦,៦ | ១ ៤៣៦,៥ | ៣ ៩៥៩,៨ |
| សណ្ឋាគារនិងភោជនីយដ្ឋាន | ៩១២,១ | ១ ០៤៥,៦ | ១ ១៩៩,២ | ១ ៣៧៩,៤ | ៣ ៦២៤,៣ |
| ដឹកជញ្ជូននិងទូរគមនាគមន៍ | ១ ០៨៤,៤ | ១ ១៩១,៧ | ១ ៣០៨,៤ | ១ ៤៣៦,៦ | ៣ ៩៣៦,៧ |
| ហិរញ្ញវត្ថុ | ២១៤,៥ | ២៣៩,៥ | ២៦៦,៧ | ២៩៧,២ | ៨០៣,២ |
| រដ្ឋបាលសាធារណៈ | ១ ៤៤២,២ | ១ ៥៣៦,៥ | ១ ៦៣១,១ | ១ ៧៣១,៤ | ៤ ៨៩៩,០ |
| អចលនវត្ថុនិងធុរកិច្ច | ៩០៤,៥ | ១ ០១១,០ | ១ ១២៥,៣ | ១ ២៥២,៤ | ៣ ៣៨៨,៧ |
| សេវាផ្សេងៗទៀត | ៥៩០,៨ | ៦៤៥,០ | ៧០៣,១ | ៧៦៥,៧ | ២ ១១៣,៩ |
| សរុប | ១៧ ៩១០,៥ | ១៩ ៩៩៥,២ | ២២ ១៤០,៩ | ២៤ ៥១៤,៧ | ៦៦ ៦៥០,៨ |

*ប្រភព: ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

## ឃ- ចំណូលនិងចំណាយថវិកា ២០១៥-២០១៧

២៣- ដោយសារវិបត្តិហិរញ្ញវត្ថុសកលលោកនិងការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចសកលលោកដែលបានកើតឡើងក្នុងប្រទេសអភិវឌ្ឍ បានជះឥទ្ធិពលអវិជ្ជមានមកលើសេដ្ឋកិច្ចកម្ពុជា ចំណូលថវិកាបានធ្លាក់ចុះពី១៣,៣ភាគរយនៃផ.ស.ស.ក្នុងឆ្នាំ២០០៨ មក១១,៩ភាគរយនៃផ.ស.ស.ក្នុងឆ្នាំ២០០៩។ ជាក់ស្តែង ចំណូលថវិកាត្រូវបានកើនឡើងវិញជាបន្តបន្ទាប់រហូតដល់១៣,២ភាគរយនៃផ.ស.ស.ក្នុងឆ្នាំ២០១០ និងបន្តរក្សានៅកម្រិតដដែលនៅក្នុងឆ្នាំ២០១១ និងបានបន្តកើនដល់១៥,២ភាគរយនៃផ.ស.ស.ក្នុងឆ្នាំ២០១២ និង១៥ភាគរយនៃផ.ស.ស.ក្នុងឆ្នាំ២០១៣ ហើយត្រូវបានព្យាករថានឹងកើនដល់ជិត១៥,៧ភាគរយ ក្នុងឆ្នាំ២០១៤ និង១៦,១ភាគរយ ក្នុងឆ្នាំ២០១៥។ ការព្យាករនេះមានកម្រិតប្រហាក់ប្រហែលទៅនឹងការរំពឹងទុក ដែលទាមទារនូវកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីសម្រេចបានកំណើនផ.ស.ស. ០,៥ភាគរយក្នុង១ឆ្នាំ សម្រាប់បំពេញតម្រូវការចំណាយចាំបាច់មួយចំនួន។

២៤- ការអនុវត្តវិធានការនានារបស់រាជរដ្ឋាភិបាលដែលផ្តោតលើការការពារក្រុមជនងាយរងគ្រោះ និងប្រជាជនក្រីក្រពីផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុសកលលោកនិងការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចសកលលោក ក៏ដូចជាការអនុវត្តវិធានការសម្រាប់ជំរុញតម្រូវការ តាមរយៈកញ្ចប់គោលនយោបាយសម្រាប់ជំរុញកំណើន ជាពិសេស ការផ្តល់ការឧបត្ថម្ភដល់កម្មករកាត់ដេរដែលបាត់បង់ការងារ កម្មករដែលបាត់បង់ការងារ និងការចំណាយច្រើនសម្រាប់កម្មវិធីកាត់បន្ថយភាពក្រីក្រ បានធ្វើឲ្យចំណាយថវិកាជាសមាមាត្រនៃផ.ស.ស.សរុប បានកើនឡើងពី១៥,៩ភាគរយក្នុងឆ្នាំ២០០៨ ដល់២០,៥ភាគរយក្នុងឆ្នាំ២០០៩ និងដល់២១,៣ភាគរយក្នុងឆ្នាំ២០១០ និងបានធ្លាក់ចុះបន្តិចមកត្រឹម២០,៧ភាគរយក្នុងឆ្នាំ២០១១ និងបានកើនដល់២១,៦ភាគរយក្នុងឆ្នាំ២០១២និងបានធ្លាក់ចុះបន្តិចមកត្រឹម២០,៨ភាគរយក្នុងឆ្នាំ២០១៣។

កម្រិតចំណាយនេះស្ថិតក្នុងរង្វង់ប្រមាណ២០ភាគរយពីឆ្នាំ២០១៤-២០១៧ ស្របតាមកិច្ចខិតខំប្រឹងប្រែងប្រមូលចំណូលបន្ថែមទៀត ដូចនេះឱនភាពថវិកាស្ថិតក្នុងកម្រិត៤ភាគរយ។

២៥- ជាផ្នែកមួយនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបាននិងកំពុងអនុវត្តដំណើរការចំនួន២ ដើម្បីផ្តល់ជាធាតុចូលក្នុងការរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ។ ទីមួយគឺ*ក្របខ័ណ្ឌចំណាយសម្រាប់រយៈមធ្យម* ដែលព្យាករពីតួលេខចំណាយចរន្តសម្រាប់រយៈពេល៣ឆ្នាំខាងមុខ។ ការព្យាករនេះនឹងត្រូវធ្វើបច្ចុប្បន្នកម្មរៀងរាល់ឆ្នាំ។ ការព្យាករផ្អែកលើការវិភាគម៉ាក្រូសេដ្ឋកិច្ចពីលើចុះក្រោម ដោយមើលលើការអនុវត្តនៃសេដ្ឋកិច្ចគោលនយោបាយអាទិភាព ក៏ដូចជាព័ត៌មានបានពីស្ថាប័ននានារបស់រាជរដ្ឋាភិបាល។ ទីពីរគឺ*ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃថវិកាសម្រាប់រយៈពេល៣ឆ្នាំ* ដែលអនុវត្តតាមអភិក្រមពីក្រោមទៅលើ។ ធាតុចូលដែលសម្រាប់យកមកប្រើប្រាស់ក្នុងការវិភាគនេះ ផ្អែកលើព័ត៌មានដែលប្រមូលបានពីការផ្លាស់ប្តូរយោបល់រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងស្ថាប័ននានារបស់រាជរដ្ឋាភិបាល និងព័ត៌មាន ស្តីពីចំណាយនិងតម្រូវការរយៈពេល៣ឆ្នាំទៅមុខនៃស្ថាប័នទាំងនោះ។ ក្នុងការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបន្តពង្រឹងភាពផ្សារភ្ជាប់គ្នានៃដំណើរការទាំងពីរ ដើម្បីកែលម្អការរៀបចំថវិកាប្រចាំឆ្នាំ។

## ខ- ចំណុចដៅនៃការកៀរគរធនធានសម្រាប់ការវិនិយោគរបស់វិស័យសាធារណៈ ឆ្នាំ២០១៤-២០១៨

២៦- រាជរដ្ឋាភិបាលបានកំណត់ចំណុចដៅនៃតម្រូវការវិនិយោគរបស់វិស័យសាធារណៈដែលអាចមានតម្លៃប្រមាណ៤៦ ២២២,៣៦ពាន់លានរៀល(១១,២៧ពាន់លានដុល្លារអាមេរិក) ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៥នៃរដ្ឋសភា។ តម្លៃប៉ាន់ស្មាននេះ រួមបញ្ចូលនូវៈ *(១)* តម្រូវការវិនិយោគមូលធនសម្រាប់វិស័យសាធារណៈដែលអាចមានប្រមាណ៣១ ១០១,៧ពាន់លានរៀល(៧,៦ពាន់លានដុល្លារអាមេរិក) *(២)* ធនធានដែលត្រូវការជាចាំបាច់ដើម្បីផ្តល់ការគាំទ្រដែលមានគោលដៅច្បាស់លាស់ដល់ការអភិវឌ្ឍ ការធ្វើពិពិធ-កម្មសេដ្ឋកិច្ចជនបទសំដៅកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទនិងតំបន់ដាច់ស្រយាល និងការផ្តល់ការគាំទ្របន្ទាន់ដល់ការសម្រាលផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុសកលលោក និងការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចសកលលោកទៅលើប្រជាជនក្រីក្រនិងប្រជាជនងាយរងគ្រោះ ដែលអាចមានប្រមាណ៧ ៥៦០,២២ពាន់លានរៀល(១,៨៤ពាន់លានដុល្លារអាមេរិក) *(៣)* ធនធានដែលត្រូវការជាចាំបាច់ ដើម្បីពង្រីកសេវាសង្គមកិច្ចសំដៅឈានទៅសម្រេចបាននូវចំណុចដៅទាំងឡាយនៃ*គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា* ដែលអាចមានប្រមាណ៣ ៧៨១,៧៣ពាន់លានរៀល(០,៩២ពាន់លានដុល្លារអាមេរិក) និង*(៤)* ធនធានដែលត្រូវការជាចាំបាច់ដើម្បីពង្រឹងសមត្ថភាពស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើតកម្មវិធីនិងការផ្តល់នូវសេវាប្រកបដោយប្រសិទ្ធភាពដែលអាចមានប្រមាណ៣ ៧៨១,៧៣ពាន់លានរៀល(០,៩២ពាន់លានដុល្លារអាមេរិក)។

**តារាងទី៥ : ចំណុចដៅនៃការត្រៀមធនធានសម្រាប់វិនិយោគរបស់វិស័យសាធារណៈ ឆ្នាំ២០១៥-២០១៧**

| តម្រូវការវិនិយោគវិស័យសាធារណៈ | ២០១៥-២០១៧ | |
|---|---|---|
| | ពាន់លានរៀល | ពាន់លាន ដុល្លារអាមេរិក |
| ១. វិនិយោគមូលធនរបស់វិស័យសាធារណៈ (ការព្យាករម៉ាក្រូសេដ្ឋកិច្ច) | ១៩ ៨៦៨,៧ | ៤,៩ |
| ២. ការគាំទ្រមានគោលដៅច្បាស់លាស់ដល់ការអភិវឌ្ឍនិងពិពិធកម្មសេដ្ឋកិច្ចជនបទ ដើម្បីកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទនិងតំបន់ដាច់ស្រយាល | ៤ ៥៣៦ | ១,១១ |
| ៣. ការពង្រីកសេវាសង្គមកិច្ច ដើម្បីឈានទៅសម្រេចបាននូវចំណុចដៅទាំងឡាយនៃគ.អ.ស.ក. | ២ ២៦៩ | ០,៥៥ |
| ៤. ការគាំទ្រដល់ការពង្រឹងសមត្ថភាពនៃស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើតកម្មវិធីនិងការផ្តល់សេវាកម្ម ប្រកបដោយប្រសិទ្ធភាព | ២ ២៦៩ | ០,៥៥ |
| **សរុប** | **២៨ ៩៤២,៧** | **៧,១** |

ប្រភព : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងផែនការ

២៧- សម្រាប់*ក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧* គឺត្រូវការថវិកាសរុបប្រមាណ១៩ ៨៦៨,៧ ពាន់លានរៀល(៤,៩ពាន់លានដុល្លារអាមេរិក) ឬប្រមាណ៦ ៦២២,៩ពាន់លានរៀល(១,៦ពាន់លានដុល្លារអាមេរិក)ក្នុងមួយឆ្នាំ។ បរិមាណថវិកាសរុបសម្រាប់អនុវត្ត*ក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧* ប្រមាណ១៩ ៨៦៨,៧ពាន់លានរៀល(៤,៩ពាន់លានដុល្លារអាមេរិក) ដែលក្នុងនោះហិរញ្ញប្បទានក្នុងស្រុកដោយរាជរដ្ឋាភិបាលមាន៤ ៨៨៣,៤ពាន់លានរៀល(១ ១៩១លានដុល្លារអាមេរិក) និងចំណែកដែលនៅសល់១៤ ៩៨៥,៣ពាន់លានរៀល(៣ ៧០៩លានដុល្លារអាមេរិក) ឬប្រមាណ ៤ ៩៩៥,១ពាន់លានរៀល(១ ២៣៦,៣លានដុល្លារអាមេរិក)ក្នុងមួយឆ្នាំ អាចត្រូវបានធ្វើហិរញ្ញប្បទានពីប្រភពដូចខាងក្រោម៖

- ហិរញ្ញប្បទានឥតសំណងពីដៃគូអភិវឌ្ឍក្រៅប្រទេសជាប្រពៃណី(ភាគច្រើនពីដៃគូអភិវឌ្ឍទ្វេភាគី ពហុភាគី និងអង្គការមិនមែនរដ្ឋាភិបាល)
- កម្ចីសម្បទានពីដៃគូអភិវឌ្ឍក្រៅប្រទេស(ភាគច្រើនពីស្ថាប័នហិរញ្ញវត្ថុពហុភាគីនិងទ្វេភាគីសំខាន់ៗ)
- ធនធានពីប្រភពដៃគូអភិវឌ្ឍមិនមែនប្រពៃណី(ហិរញ្ញប្បទានឥតសំណងនិងកម្ចីពាក់កណ្តាលសម្បទាន) និង
- ចំណូលថ្មីៗដែលអាចបានមកពីការអភិវឌ្ឍឧស្សាហកម្មអាជីវកម្មរ៉ែ។

២៨- រាជរដ្ឋាភិបាលកម្ពុជាមានជំនឿជឿជាក់ថា តម្រូវការវិនិយោគសម្រាប់វិស័យសាធារណៈដែលមានប្រមាណ១៤ ៩៨៥,៣ពាន់លានរៀល(៣ ៧០៩លានដុល្លារអាមេរិក) ឬប្រមាណ៤ ៩៩៥,១ពាន់លានរៀល(១ ២៣៦,៣លានដុល្លារអាមេរិក)ក្នុងមួយឆ្នាំ អាចនឹងទទួលបានពីការបន្តគាំទ្រ

ពីដៃគូអភិវឌ្ឍជាប្រពៃណីនិងមិនមែនជាប្រពៃណី និងពីចំណូលបន្ថែមថ្មីពីប្រេង ឧស្ម័ន និងធនធានរ៉ែ នៅពេលដែលអាជីវកម្មនេះត្រូវបានដំណើរការជាលក្ខណៈពាណិជ្ជកម្ម។ ក៏ប៉ុន្តែការកៀរគរហិរញ្ញប្បទានបន្ថែមពីដៃគូ ដូចជាមិនបានបង្ហាញពីភាពងាយស្រួលឡើយ ដោយសារដៃគូភាគច្រើនបានសន្យាផ្តល់រួចមកហើយ និងដើម្បីសម្រេចបានហិរញ្ញប្បទានគ្រប់ចំនួន គឺត្រូវខិតខំស្វែងរកបន្ថែមទៀតនូវដៃគូថ្មីផ្សេងៗទៀត។ សម្រាប់រាជរដ្ឋាភិបាល គឺត្រូវពិនិត្យឲ្យច្បាស់លាស់នូវកំណែទម្រង់សេដ្ឋកិច្ច ដូចជាការបង្កើនទិន្នផលស្រូវនិងការនាំចេញ និងការធ្វើពិពិធកម្មដំណាំផ្សេងៗក្រៅពីដំណាំស្រូវ ជាពិសេស សម្រាប់អនាគត ត្រូវគ្រប់គ្រងចំណូលទទួលបានពីអាជីវកម្មរ៉ែ ដីសម្បទាន និងចំណូលពន្ធ។

២៩- វិភាជន៍តាមវិស័យនិងអនុវិស័យនៃតម្រូវការវិនិយោគសម្រាប់វិស័យសាធារណៈ សម្រាប់ឆ្នាំ ២០១៥-២០១៧ នៅក្នុងតារាងទី៦ខាងក្រោម គឺមានមូលដ្ឋានពីការវិភាជតាមវិស័យនិងអនុវិស័យ ចែងនៅក្នុងតារាងទី៥.៣ នៃ*ផ.យ.អ.ជ. ២០១៤-២០១៨*។

**តារាងទី៦ : ការវិភាជតាមវិស័យនិងអនុវិស័យសម្រាប់តម្រូវការវិនិយោគសម្រាប់វិស័យសាធារណៈ ដោយមានមូលដ្ឋានពីការវិភាជតាមវិស័យនិងអនុវិស័យចែងនៅក្នុងផ.យ.អ.ជ. ២០១៤-២០១៨**

| វិស័យ | ភាគរយ | បរិមាណវិភាជន៍ ២០១៥-២០១៧ | |
|---|---|---|---|
| | | ពាន់លានរៀល | លានដុល្លារអាមេរិក |
| **វិស័យសង្គមកិច្ច** | | | |
| អប់រំ : ក្នុងនោះការអប់រំមូលដ្ឋាន៦០% | ១២ | ២ ៣៨៤,២ | ៥៨៨,០ |
| បច្ចេកទេសនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៤ | ៧៩៤,៧ | ១៩៦,០ |
| សុខាភិបាល | ១២ | ២ ៣៨៤,២ | ៥៨៨,០ |
| កម្មវិធីជួយកាត់បន្ថយផលប៉ះពាល់ដែលបណ្តាលមកពីវិបត្តិហិរញ្ញវត្ថុសកលលោកលើជនងាយរងគ្រោះនិងអ្នកក្រ | ៤ | ៧៩៤,៧ | ១៩៦,០ |
| សរុប | **៣២** | **៦ ៣៥៧,៩** | **១ ៥៦៨,០** |
| **វិស័យសេដ្ឋកិច្ច** | | | |
| កសិកម្មនិងការគ្រប់គ្រងដីធ្លី | ៤ | ៧៩៤,៧ | ១៩៦,០ |
| ដំណាំតាមរដូវ : ស្រូវនិងដំណាំផ្សេងៗ | ៤ | ៧៩៤,៧ | ១៩៦,០ |
| អភិវឌ្ឍន៍ជនបទ | ១២ | ២ ៣៨៤,២ | ៥៨៨,០ |
| កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម | ៤ | ៧៩៤,៧ | ១៩៦,០ |
| សរុប | **២៤** | **៤ ៧៦៨,៣** | **១ ១៧៦,០** |
| **វិស័យហេដ្ឋារចនាសម្ព័ន្ធ** | | | |
| ដឹកជញ្ជូន (ផ្លូវថ្នល់ កំពង់ផែ ផ្លូវដែក អាកាសចរណ៍) | ១២ | ២ ៣៨៤,២ | ៥៨៨,០ |
| ទឹកនិងអនាម័យ (មិនគិតនៅជនបទ) | ៤ | ៧៩៤,៧ | ១៩៦,០ |
| ថាមពលនិងអគ្គិសនី | ៤ | ៧៩៤,៧ | ១៩៦,០ |
| ប្រៃសណីយ៍និងទូរគមនាគមន៍ | ១ | ១៩៨,៧ | ៤៩,០ |
| សរុប | **២១** | **៤ ១៧២,៣** | **១ ០២៩,០** |

| | | | |
|---|---|---|---|
| **សេវាកម្មនិងកម្មវិធីអន្តរវិស័យ** | | | |
| ការបញ្ជ្រាបយេនឌ័រ | ១,៥ | ២៩៨,០ | ៧៣,៥ |
| ទេសចរណ៍ | ២ | ៣៩៧,៤ | ៩៨,០ |
| បរិស្ថាននិងការអភិវឌ្ឍ | ៤ | ៧៩៤,៧ | ១៩៦,០ |
| សហគមន៍និងសេវាកម្មសង្គម | ៤ | ៧៩៤,៧ | ១៩៦,០ |
| វប្បធម៌និងសិល្បៈ | ១,៥ | ២៩៨,០ | ៧៣,៥ |
| អភិបាលកិច្ចនិងរដ្ឋបាល | ៨ | ១ ៥៨៩,៥ | ៣៩២,០ |
| **សរុប** | **២១** | **៤ ១៧២,៣** | **១ ០២៩,០** |
| **សរុបរួម** | **១០០** | **១៩ ៨៦៨,៧** | **៤ ៩០០,០** |

*ប្រភព: ផ.យ.អ.ជ.២០១៤-២០១៨*

# ជំពូកទី៣

## កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០១៥-២០១៧

៣០- ដូចបានបង្ហាញក្នុងជំពូកមុនដែរ សម្រាប់ការអនុវត្ត *ផ.យ.អ.ជ. ២០១៤-២០១៨* (រយៈពេល ៥ឆ្នាំ) រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការប៉ាន់ស្មានតម្លៃសរុបចំនួន៣១ ១០១,៧ពាន់លានរៀល (៧ ៦០០លានដុល្លារអាមេរិក) សម្រាប់បំពេញតម្រូវការវិនិយោគវិស័យសាធារណៈ ដើម្បីសម្រេចបាននូវការអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលនីតិកាលទី៥។ ការវិភាជសម្រាប់ *ក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧* មានចំនួន១៩ ៨៦៨,៧ពាន់លានរៀល(៤,៩ពាន់លានដុល្លារអាមេរិក) (តារាងទី៧) និងដូចមានចែងនៅក្នុងក្របខ័ណ្ឌចំណាយសម្រាប់រយៈពេលមធ្យម គឺរាជរដ្ឋាភិបាលកម្ពុជាបានវិភាជថវិកាជាតិចំនួន៤ ៨៨៣,៤ពាន់លានរៀល (១ ១៩១លានដុល្លារអាមេរិក) សម្រាប់ *ក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧*។

**តារាងទី៧ : ការវិភាជតាមវិស័យនិងអនុវិស័យ សម្រាប់តម្រូវការវិនិយោគវិស័យសាធារណៈ ចែងនៅក្នុង ផ.យ.អ.ជ. ២០១៤-២០១៨ និងក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧**

| វិស័យ និងអនុវិស័យ | គោលដៅវិនិយោគសាធារណៈក្នុងផ.យ.អ.ជ. ២០១៤-២០១៨ | | | | | |
|---|---|---|---|---|---|---|
| | ផ.យ.អ.ជ. ២០១៤-២០១៨ | | | ក.វ.ស. ២០១៥-២០១៧ | | |
| | ភាគរយ | ពាន់លានរៀល | លានដុល្លារអាមេរិក | ពាន់លានរៀល | លានដុល្លារអាមេរិក | ភាគរយ |
| **វិស័យសង្គមកិច្ច** | | | | | | |
| អប់រំ : ក្នុងនោះការអប់រំមូលដ្ឋាន៦០% | ១២ | ៣ ៧៣២,៨ | ៩១២,០ | ២ ៣៨៤,២ | ៥៨៨,០ | ១២ |
| បច្ចេកទេសនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៤ | ១ ២៤៤,៣ | ៣០៤,០ | ៧៩៤,៧ | ១៩៦,០ | ៤ |
| សុខាភិបាល | ១២ | ៣ ៧៣២,៨ | ៩១២,០ | ២ ៣៨៤,២ | ៥៨៨,០ | ១២ |
| កម្មវិធីជួយកាត់បន្ថយផលប៉ះពាល់ដែលបណ្តាលមកពីវិបត្តិហិរញ្ញវត្ថុសកលលោកលើជនងាយរងគ្រោះនិងអ្នកក្រ | ៤ | ១ ២៤៤,៣ | ៣០៤,០ | ៧៩៤,៧ | ១៩៦,០ | ៤ |
| សរុប | **៣២** | **៩ ៩៥៤,២** | **២ ៤៣២,០** | **៦ ៣៩៧,៩** | **១ ៥៦៨,០** | **៣២** |
| **វិស័យសេដ្ឋកិច្ច** | | | | | | |
| កសិកម្មនិងការគ្រប់គ្រងដីធ្លី | ៤ | ១ ២៤៤,៣ | ៣០៤,០ | ៧៩៤,៧ | ១៩៦,០ | ៤ |
| ដំណាំតាមរដូវ : ស្រូវនិងដំណាំផ្សេងៗ | ៤ | ១ ២៤៤,៣ | ៣០៤,០ | ៧៩៤,៧ | ១៩៦,០ | ៤ |
| អភិវឌ្ឍន៍ជនបទ | ១២ | ៣ ៧៣២,៨ | ៩១២,០ | ២ ៣៨៤,២ | ៥៨៨,០ | ១២ |
| កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម | ៤ | ១ ២៤៤,៣ | ៣០៤,០ | ៧៩៤,៧ | ១៩៦,០ | ៤ |
| សរុប | **២៤** | **៧ ៤៦៥,៧** | **១ ៨២៤,០** | **៤ ៧៦៨,៣** | **១ ១៧៦,០** | **២៤** |
| **វិស័យហេដ្ឋារចនាសម្ព័ន្ធ** | | | | | | |
| ដឹកជញ្ជូន (ផ្លូវថ្នល់ កំពង់ផែ ផ្លូវដែក | ១២ | ៣ ៧៣២,៨ | ៩១២,០ | ២ ៣៨៤,២ | ៥៨៨,០ | ១២ |

| | | | | | | |
|---|---|---|---|---|---|---|
| អាកាសចរណ៍) | | | | | | |
| ទឹកនិងអនាម័យ (មិនគិតនៅជនបទ) | ៤ | ១ ២៤៤,៣ | ៣០៤,០ | ៧៩៤,៧ | ១៩៦,០ | ៤ |
| ថាមពលនិងអគ្គិសនី | ៤ | ១ ២៤៤,៣ | ៣០៤,០ | ៧៩៤,៧ | ១៩៦,០ | ៤ |
| ប្រៃសណីយ៍និងទូរគមនាគមន៍ | ១ | ៣១១,១ | ៧៦,០ | ១៩៨,៧ | ៤៩,០ | ១ |
| **សរុប** | **២១** | **៦ ៥៣២,៥** | **១ ៥៩៦,០** | **៤ ១៧២,៣** | **១ ០២៩,០** | **២១** |
| **សេវាកម្មនិងកម្មវិធីអន្តរវិស័យ** | | | | | | |
| ការបញ្ច្រាបយេនឌ័រ | ១,៥ | ៤៦៦,៦ | ១១៤,០ | ២៩៨,០ | ៧៣,៥ | ១,៥ |
| ទេសចរណ៍ | ២ | ៦២២,១ | ១៥២,០ | ៣៩៧,៤ | ៩៨,០ | ២ |
| បរិស្ថាននិងការអភិវឌ្ឍ | ៤ | ១ ២៤៤,៣ | ៣០៤,០ | ៧៩៤,៧ | ១៩៦,០ | ៤ |
| សហគមន៍និងសេវាកម្មសង្គម | ៤ | ១ ២៤៤,៣ | ៣០៤,០ | ៧៩៤,៧ | ១៩៦,០ | ៤ |
| វប្បធម៌និងសិល្បៈ | ១,៥ | ៤៦៦,៦ | ១១៤,០ | ២៩៨,០ | ៧៣,៥ | ១,៥ |
| អភិបាលកិច្ចនិងរដ្ឋបាល | ៨ | ២ ៤៨៨,៦ | ៦០៨,០ | ១ ៥៨៩,៥ | ៣៩២,០ | ៨ |
| **សរុប** | **២១** | **៦ ៥៣២,៥** | **១ ៥៩៦,០** | **៤ ១៧២,៣** | **១ ០២៩,០** | **២១** |
| **មិនទាន់បែងចែក** | ២ | ៦២២,១ | ១៥២,០ | ៣៩៧,៤ | ៩៨,០ | ២ |
| **សរុបរួម** | **១០០** | **៣១ ១០៧,០** | **៧ ६០០,០** | **១៩ ៨៦៨,៧** | **៤ ៩០០,០** | **១០០** |

*ប្រភព : ផ.យ.អ.ជ. ២០១៤-២០១៨*

## ក- សេចក្តីសង្ខេបនៃគម្រោងសម្រាប់ក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧ ដែលបានទទួលពីក្រសួង ស្ថាប័ន

៣១- *ក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧* បានរៀបចំឡើងដោយមានមូលដ្ឋានលើធាតុចូលដែលបានទទួលពីគ្រប់ក្រសួង ស្ថាប័ន រួមមាន៖ *(១) គម្រោងកំពុងដំណើរការ* ជាគម្រោងដែលកំពុងអនុវត្តដោយមានឬពុំមានកិច្ចសហការប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និង*(២) គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.(គម្រោងថ្មី)* ដែលក្រសួង ស្ថាប័ន មានគម្រោងអនុវត្តក្នុងអំឡុងពេលឆ្នាំ ២០១៥-២០១៧។ *ផ.យ.អ.ជ. ២០១៤-២០១៨* បានថែងថាបរិមាណថវិកាចំនួន៧,៦០ពាន់លានដុល្លារអាមេរិក នឹងត្រូវចំណាយសម្រាប់តម្រូវការវិនិយោគវិស័យសាធារណៈសម្រាប់រយៈពេល៥ឆ្នាំ២០១៤-២០១៨ ចំណែកឯតម្រូវការវិនិយោគវិស័យសាធារណៈនៃ*ក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧* មានចំនួន៤,៩ពាន់លានដុល្លារអាមេរិក។ ក៏ប៉ុន្តែក្រសួង ស្ថាប័ន ស្នើសុំសម្រាប់ដាក់បញ្ចូលទៅក្នុង*ក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧* មានចំនួន៥ ២៤៣លានដុល្លារអាមេរិក។ ព័ត៌មានសង្ខេបស្តីពីគម្រោង*ក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧* ដែលបានស្នើឡើងដោយក្រសួង ស្ថាប័ន មានបង្ហាញនៅក្នុងតារាងទី៨៖

- តម្រូវការចំណាយប៉ាន់ស្មានសរុបសម្រាប់*ក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧* តម្រូវការថវិកាសរុប៥ ២៤៣លានដុល្លារអាមេរិក។
  - គម្រោងកំពុងដំណើរការ ២ ៨៦៥លានដុល្លារអាមេរិក
  - គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.(ថ្មី) ២ ៣៧៨លានដុល្លារអាមេរិក

- បរិមាណថវិកាដែលក្រសួង ស្ថាប័នបានរាយការណ៍ថា បានសន្យាផ្តល់៣ ៨២៥,៥លានដុល្លារអាមេរិក
  - ▪ ថវិកាជាតិ ៥២៤,៦លានដុល្លារអាមេរិក
  - ▪ ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ ៣ ៣០០,៩លានដុល្លារអាមេរិក
    - ▪ សម្រាប់គម្រោងកំពុងដំណើរការ ២ ៧៤៥,៨លានដុល្លារអាមេរិក
      - ថវិកាជាតិ ៣១៣,៤លានដុល្លារអាមេរិក
      - ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ ២ ៤៣២,៣លានដុល្លារអាមេរិក
    - ▪ សម្រាប់គម្រោងអនុវត្តផ.យ.អ.ជ.(ថ្មី) ១ ០៧៩,៧លានដុល្លារអាមេរិក
      - ថវិកាជាតិ ២១១,១លានដុល្លារអាមេរិក
      - ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ ៨៦៨,៦លានដុល្លារអាមេរិក
- តម្រូវការថវិកាបំពេញបន្ថែម(បំពេញបន្ថែមបរិមាណហិរញ្ញប្បទានដែលបានសន្យា) ១ ៤១៧,៤លានដុល្លារអាមេរិក
  - ▪ គម្រោងកំពុងដំណើរការ ១១៩,១លានដុល្លារអាមេរិក
  - ▪ គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. ១ ២៩៨,៣លានដុល្លារអាមេរិក

៣២- តារាងទី៩ នឹងធ្វើការបង្ហាញលម្អិតបន្ថែមនូវគម្រោងដែលក្រសួង ស្ថាប័នទាំងអស់ បានផ្ញើមកក្រសួងផែនការសម្រាប់ធ្វើការរៀបចំ*ក.វ.ស. ៣ឆ្នាំរំកិល២០១៥-២០១៧* និងបានបែងចែកគម្រោងទាំងអស់នោះទៅតាមវិស័យអាទិភាពរបស់*ផ.យ.អ.ជ. ២០១៤-២០១៨*។ ព័ត៌មានគម្រោងទាំងនោះរួមមាន (១) តម្រូវការចំណាយប៉ាន់ស្មានសរុបទៅតាមឆ្នាំនីមួយៗពីឆ្នាំ២០១៥-២០១៧ (២) បរិមាណហិរញ្ញប្បទានដែលក្រសួង ស្ថាប័នបានរាយការណ៍ថាបានសន្យាផ្តល់ (ដោយរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ) សម្រាប់គម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. និង(៣) បរិមាណតម្រូវការហិរញ្ញប្បទានបំពេញបន្ថែមលើហិរញ្ញប្បទានដែលបានសន្យាផ្តល់រួចហើយក្នុងឆ្នាំនីមួយៗ។

# តារាងទី៨ : សេចក្តីសង្ខេបស្តីពីគម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. ដែលក្រសួង ស្ថាប័នស្នើសុំសម្រាប់ក.វ.ស. បីឆ្នាំរំកិល២០១៥-២០១៧

*(គិតជាពាន់ដុល្លារអាមេរិក)*

| | ចំណាយប៉ាន់ស្មានសរុប | | | | ហិរញ្ញប្បទានបានសន្យាផ្តល់ | | | | | តម្រូវការហិរញ្ញប្បទានបំពេញបន្ថែម | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ | សរុប ២០១៥-២០១៧ | ប្រភព ហិរញ្ញប្បទាន | ២០១៥ | ២០១៦ | ២០១៧ | សរុប ២០១៥-២០១៧ | ២០១៥ | ២០១៦ | ២០១៧ | សរុប ២០១៥-២០១៧ |
| គម្រោងកំពុងដំណើរការ | | | | | រាជរដ្ឋាភិបាល | 93,240.2 | 124,075.8 | 96,161.7 | 313,477.7 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 1,031,441.1 | 938,893.6 | 461,803.4 | 2,432,358.2 | | | | |
| | 1,140,000.0 | 1,109,000.0 | 616,000.0 | 2,865,000.0 | សរុប | 1,124,681.4 | 1,062,969.4 | 557,965.1 | 2,745,835.8 | 15,318.7 | 46,030.6 | 58,034.9 | 119,164.2 |
| គម្រោងសម្រាប់អនុវត្ត ផយអជ | | | | | រាជរដ្ឋាភិបាល | 86,137.8 | 81,956.8 | 43,057.8 | 211,152.3 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 308,106.4 | 352,367.3 | 208,114.8 | 868,588.5 | | | | |
| | 628,000.0 | 670,000.0 | 1,080,000.0 | 2,378,000.0 | សរុប | 394,244.2 | 434,324.0 | 251,172.5 | 1,079,740.7 | 233,755.8 | 235,676.0 | 828,827.5 | 1,298,259.3 |
| សរុប | | | | | រាជរដ្ឋាភិបាល | 179,378.0 | 206,032.5 | 139,219.4 | 524,629.9 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 1,339,547.6 | 1,291,260.9 | 669,918.1 | 3,300,946.6 | | | | |
| | 1,768,000.1 | 1,779,000.0 | 1,696,000.0 | 5,243,000.1 | សរុប | 1,518,925.6 | 1,497,293.4 | 809,137.6 | 3,825,576.5 | 249,074.5 | 281,706.6 | 886,862.4 | 1,417,423.5 |

# តារាងទី ៩ : គម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្តផ .យ.អ.ជ. បែងចែកទៅតាមវិស័យអាទិភាពនៃផ.យ.អ.ជ.២០១៤-២០១៨ ដែលក្រសួង ស្ថាប័នស្នើសុំ

(ឯកតាគិតជាពាន់ដុល្លារអាមេរិក)

| ក្រសួង ស្ថាប័ន | ចំណាយប៉ាន់ស្មានសរុប | | | | ហិរញ្ញប្បទានបានសន្យាផ្តល់ | | | | | តម្រូវការហិរញ្ញប្បទានបំពេញបន្ថែម | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ | សរុប ២០១៥-២០១៧ | ប្រភព ហិរញ្ញប្បទាន | ២០១៥ | ២០១៦ | ២០១៧ | សរុប ២០១៥-២០១៧ | ២០១៥ | ២០១៦ | ២០១៧ | សរុប ២០១៥-២០១៧ |
| **វិស័យសង្គមកិច្ច** | | | | | | | | | | | | | |
| គម្រោងកំពុងដំណើរការ | 224,721.8 | 184,143.0 | 131,418.6 | 540,283.4 | សរុប | 212,618.2 | 140,651.5 | 76,423.6 | 429,913.3 | 12,103.6 | 43,491.4 | 54,995.0 | 110,370.1 |
| | | | | | រាជរដ្ឋាភិបាល | 17,638.1 | 17,979.5 | 17,024.1 | 52,641.7 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 194,980.1 | 122,672.0 | 59,399.5 | 377,271.6 | | | | |
| គម្រោងសម្រាប់អនុវត្ត ផយអជ | 18,687.5 | 17,243.5 | 35,395.5 | 71,326.6 | សរុប | 4,425.0 | 4,224.0 | 3,420.0 | 12,069.0 | 14,262.5 | 13,019.5 | 31,975.5 | 59,257.6 |
| | | | | | រាជរដ្ឋាភិបាល | 242.8 | 231.8 | 192.8 | 667.3 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 4,182.3 | 3,992.3 | 3,227.3 | 11,401.8 | | | | |
| សរុប | 243,409.3 | 201,386.5 | 166,814.2 | 611,610.0 | សរុប | 217,043.2 | 144,875.5 | 79,843.6 | 441,982.3 | 26,366.1 | 56,511.0 | 86,970.6 | 169,627.7 |
| | | | | | រាជរដ្ឋាភិបាល | 17,880.9 | 18,211.2 | 17,216.8 | 53,308.9 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 199,162.3 | 126,664.3 | 62,626.8 | 388,673.4 | | | | |
| **1. ក្រសួងសុខាភិបាល** | | | | | | | | | | | | | |
| គម្រោងកំពុងដំណើរការ | 78,276.1 | 68,206.9 | 63,542.9 | 210,026.0 | សរុប | 70,551.2 | 31,313.1 | 22,485.8 | 124,570.1 | 7,724.9 | 36,893.8 | 41,057.2 | 85,455.9 |
| | | | | | រាជរដ្ឋាភិបាល | 11,700.3 | 12,119.7 | 12,630.3 | 36,450.3 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 58,851.0 | 19,193.4 | 9,855.5 | 88,119.8 | | | | |
| គម្រោងសម្រាប់អនុវត្ត ផយអជ | 880.0 | 880.0 | 350.0 | 2,110.0 | សរុប | 70.0 | 70.0 | 65.0 | 205.0 | 810.0 | 810.0 | 285.0 | 1,905.0 |
| | | | | | រាជរដ្ឋាភិបាល | 25.0 | 25.0 | 25.0 | 75.0 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 45.0 | 45.0 | 40.0 | 130.0 | | | | |
| សរុប | 79,156.1 | 69,086.9 | 63,892.9 | 212,136.0 | សរុប | 70,621.2 | 31,383.1 | 22,550.8 | 124,775.1 | 8,534.9 | 37,703.8 | 41,342.2 | 87,360.9 |
| | | | | | រាជរដ្ឋាភិបាល | 11,725.3 | 12,144.7 | 12,655.3 | 36,525.3 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 58,896.0 | 19,238.4 | 9,895.5 | 88,249.8 | | | | |
| **2. ក្រសួងអប់រំ យុវជន និងកីឡា** | | | | | | | | | | | | | |
| គម្រោងកំពុងដំណើរការ | 87,588.3 | 55,590.8 | 4,500.0 | 147,679.1 | សរុប | 87,588.3 | 55,590.8 | 4,500.0 | 147,679.1 | | | | |
| | | | | | រាជរដ្ឋាភិបាល | 1,200.0 | 1,200.0 | 200.0 | 2,600.0 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 86,388.3 | 54,390.8 | 4,300.0 | 145,079.1 | | | | |

| ក្រសួង ស្ថាប័ន | ចំណាយប៉ាន់ស្មានសរុប | | | | ហិរញ្ញប្បទានបានសន្យាផ្តល់ | | | | | តម្រូវការហិរញ្ញប្បទានបំពេញបន្ថែម | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ | សរុប ២០១៥-២០១៧ | ប្រភពហិរញ្ញប្បទាន | ២០១៥ | ២០១៦ | ២០១៧ | សរុប ២០១៥-២០១៧ | ២០១៥ | ២០១៦ | ២០១៧ | សរុប ២០១៥-២០១៧ |
| គម្រោងសម្រាប់អនុវត្ត ផយអជ | 10,114.9 | 9,999.0 | 30,499.0 | 50,613.0 | សរុប | | | | | 10,114.9 | 9,999.0 | 30,499.0 | 50,613.0 |
| | | | | | រាជរដ្ឋាភិបាល | | | | | | | | |
| | | | | | ដៃគូអភិវឌ្ឍ | | | | | | | | |
| សរុប | 97,703.2 | 65,589.9 | 34,999.0 | 198,292.1 | សរុប | 87,588.3 | 55,590.8 | 4,500.0 | 147,679.1 | 10,114.9 | 9,999.0 | 30,499.0 | 50,613.0 |
| | | | | | រាជរដ្ឋាភិបាល | 1,200.0 | 1,200.0 | 200.0 | 2,600.0 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 86,388.3 | 54,390.8 | 4,300.0 | 145,079.1 | | | | |
| **3. ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ** | | | | | | | | | | | | | |
| គម្រោងកំពុងដំណើរការ | 10,100.0 | 7,150.0 | 7,500.0 | 24,750.0 | សរុប | 10,100.0 | 7,150.0 | 7,500.0 | 24,750.0 | | | | |
| | | | | | រាជរដ្ឋាភិបាល | 300.0 | | | 300.0 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 9,800.0 | 7,150.0 | 7,500.0 | 24,450.0 | | | | |
| គម្រោងសម្រាប់អនុវត្ត ផយអជ | 7,692.6 | 6,364.5 | 4,546.5 | 18,603.6 | សរុប | 4,355.0 | 4,154.0 | 3,355.0 | 11,864.0 | 3,337.6 | 2,210.5 | 1,191.5 | 6,739.6 |
| | | | | | រាជរដ្ឋាភិបាល | 217.8 | 206.8 | 167.8 | 592.3 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 4,137.3 | 3,947.3 | 3,187.3 | 11,271.8 | | | | |
| សរុប | 17,792.6 | 13,514.5 | 12,046.5 | 43,353.6 | សរុប | 14,455.0 | 11,304.0 | 10,855.0 | 36,614.0 | 3,337.6 | 2,210.5 | 1,191.5 | 6,739.6 |
| | | | | | រាជរដ្ឋាភិបាល | 517.8 | 206.8 | 167.8 | 892.3 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 13,937.3 | 11,097.3 | 10,687.3 | 35,721.8 | | | | |
| **4. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** | | | | | | | | | | | | | |
| គម្រោងកំពុងដំណើរការ | 48,757.4 | 53,195.2 | 55,875.7 | 157,828.3 | សរុប | 44,378.7 | 46,597.6 | 41,937.9 | 132,914.2 | 4,378.7 | 6,597.6 | 13,937.9 | 24,914.2 |
| | | | | | រាជរដ្ឋាភិបាល | 4,437.9 | 4,659.8 | 4,193.8 | 13,291.4 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 39,940.8 | 41,937.9 | 37,744.1 | 119,622.7 | | | | |
